**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងមហាផ្ទៃ**

លេខ : ១២៦/២៤ មស.គ.ក.ស

# សេចក្តីណែនាំអន្តរក្រសួង
# ស្តីពី
# ការបើកផ្តល់បៀវត្ស និងការគ្រប់គ្រងការផ្ទេរបុគ្គលិកអប់រំទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

យោងអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងតាមស្មារតីកិច្ចប្រជុំអន្តរក្រសួង ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ រវាងក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ និងដើម្បីធានាឱ្យការបើកផ្តល់បៀវត្សជូនបុគ្គលិកអប់រំ និងការគ្រប់គ្រងការផ្ទេរបុគ្គលិកអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា និងមានប្រសិទ្ធភាពចាប់ពីខែ**មករា ឆ្នាំ២០២៤** ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

**១.** ការបើកផ្តល់បៀវត្សជូនបុគ្គលិកអប់រំដែលត្រូវផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តផ្អែកលើតារាងទូទាត់បៀវត្សផ្តល់ដោយក្រសួងមុខងារសាធារណៈ និងប្រើប្រាស់ឥណទានដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់បន្ទុកបុគ្គលិកគ្រូបង្រៀន នៃសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា ព្រមទាំងមន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនជាប់កិច្ចសន្យា ដែលផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**២.** ការបើកផ្តល់បៀវត្សដល់បុគ្គលិកអប់រំ ត្រូវអនុវត្តតាមគណនីធនាគាររបស់បុគ្គលិកអប់រំធ្លាប់ប្រើកន្លងមក ដោយមិនអនុញ្ញាតឱ្យមានការផ្លាស់ប្តូរធនាគារនោះទេ។

**៣.** រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរក្សាប្រក្រតីភាព និងនិរន្តរភាពការងារនៅតាមសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ និងអង្គភាពនីមួយៗ ដោយមិនត្រូវធ្វើការផ្លាស់ប្តូរ ឬការផ្ទេរមន្ត្រីនៅតាមសាលា មជ្ឈមណ្ឌល និងអង្គភាពទាំងនោះឡើយ។

**៤.** រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចេញដីកាទទួលបុគ្គលិកអប់រំដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយមានការបញ្ជាក់អំពីអង្គភាពបំពេញការងាររបស់បុគ្គលិកអប់រំ ផ្អែកលើលក្ខខណ្ឌចំនួន២ ដូចខាងក្រោម៖

- បញ្ជីឈ្មោះផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡា និងដែលមានការឯកភាពពីមន្ទីរមុខងារសាធារណៈ និង
- ស្ថានភាពជាក់ស្តែងរបស់បុគ្គលិកអប់រំដែលកំពុងបំពេញការងារតាមសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ អង្គភាពរដ្ឋបាលចំណុះឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**៥.** ក្នុងករណីមានបុគ្គលិកអប់រំមិនស្ថិតក្នុងលក្ខខណ្ឌទាំងពីរ នៃចំណុច ៤ ខាងលើនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍បញ្ជាក់អំពីស្ថានភាពដោយឡែកនីមួយៗ រួមមានករណី៖

- បុគ្គលិកអប់រំដែលមានឈ្មោះនៅក្នុងបញ្ជីផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡា និងដែលមានការឯកភាពពីមន្ទីរមុខងារសាធារណៈ ប៉ុន្តែពុំមានវត្តមានបំពេញការងារជាក់ស្តែងនៅតាមសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬអង្គភាពរដ្ឋបាលចំណុះឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

- បុគ្គលិកអប់រំដែលកំពុងបំពេញការងារនៅទីតាំងជាក់ស្តែង តាមសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬអង្គភាពរដ្ឋបាលចំណុះឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប៉ុន្តែពុំមានឈ្មោះនៅក្នុងបញ្ជីផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡា និងដែលមានការឯកភាពពីមន្ទីរមុខងារសាធារណៈ។

របាយការណ៍ខាងលើនេះ ត្រូវបញ្ជូនមកមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈ ដើម្បីរាយការណ៍ជូនសាមីក្រសួង ពិនិត្យនិងសម្រេច។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រី ប្រធានមន្ទីរ គ្រប់អង្គភាពពាក់ព័ន្ធ និងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត
- រតនាគារ រាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ